# Luxation and Elevators

Luxation: ជាការប្រើកំលាំងដើម្បីញែករវាងរឹសធ្មេញ និង ឆ្អឹងនៅជុំវិញដែលអាចជួយដល់ការឱ្យធ្មេញរង្គើរពី socket គួរធ្វើមុនការប្រើដង្កាប ដែលអាចបញ្ជាក់ថា ធ្មេញមានសភាពរង្គើរដើម្បីដកចេញ។ ផ្នែកចុងរបស់វាមានលក្ខណៈ កោង និង មូលហើយ អាចត្រង់ រឺ កែងតាមទំហំតូច រឺ ធំ។





Coupland's chisel ត្រូវបានប្រើក្នុងការគាស់ និង ញែកធ្មេញពីជាលិកា ជុំវិញធ្មេញដែលធ្វើឱ្យធ្មេញរង្គើរ នៅក្នុង forceps ហើយងាយស្រួលក្នុងការ ដក ដោយប្រើ chisel នេះមានទំហំបីខុសគ្នា។




Elevator ត្រូវបានប្រើសំរាប់ការយករឹស រឺផ្នែកនៃរឹសចេញ។ ផ្នែកខាងចុងនៃ Cryer elevator រឺផ្នែកចុងមូលរបស់ Warwick James elevator ត្រូវបានប្រើសំរាប់ការ យកនូវបំនែក១របស់រឹសធ្មេញចេញពី socket ។




